

# ពានរ

# PRIMATES

*ដោយៈ រដ្ឋបាលព្រៃឈើ*

បច្ចុប្បន្ននៅប្រទេសកម្ពុជា គេបានកត់ត្រាឃើញមានពពួកពានរចំនួន១១ប្រភេទ។ គ្រប់ក្រុមប្រភេទសត្វពានរទាំងអស់ស្ថិតនៅក្នុងលំដាប់ថ្នាក់ Primates និងមានរប៉ាយរស់នៅគ្រប់ទីកន្លែងនៃពិភពលោក។ ប្រទេសកម្ពុជាមានក្រុមស្វាដែលស្ថិតនៅក្នុងអំបូរ Cercopithecidae ( រួមមានស្វាក្តាម ស្វាត្រោស ស្វាអង្គត់ ស្វាព្រាម ស្វាកន្ទុយស និងស្វា កន្ទុយសជើងក្រហម) ក្រុមរញ្ជីស្ថិតក្នុងអំបូរ Lorisidae (រួមមានរញ្ជីប្រផេះ និងរញ្ជីភ្លើង) និងក្រុមសត្វទោចដែលស្ថិត ក្នុងអំបូរ Hylobatidae (រួមមានទោចម្កុដ ទោចថ្ពាល់លឿង និងទោចប្រភេទ Northern buffed-checked gibbon )។ ពពួកពានរភាគច្រើនរស់នៅគ្រប់ប្រភេទទីជម្រកនៃតំបន់ ព្រៃឈើតំបន់ខ្ពង់រាបដែលមានរយៈកម្ពស់ខ្ពស់ជាង ១៦០០ ម៉ែត្រពីនីវូសមុទ្រ តំបន់ទំនាបគ្រប់ប្រភេទ តំបន់ព្រៃលិចទឹក និងព្រៃកោងកាង។ ក្រុមខ្លះមានសមត្ថភាពហែលទឹកយ៉ាងជំនាញទៀតផង។ ដោយសារការសម្បូរចំណី និង ទីជម្រកក្រុមពានរនៅប្រទេសកម្ពុជាមានលទ្ធភាពខ្ពស់ ក្នុងការបន្តពូជ ទាំងក្នុងមជ្ឈដ្ឋានធម្ម " ជាតិ និងការអភិរក្សក្រៅតំបន់។ ប៉ុន្តែជាអកុសលប្រភេទខ្លះកំពុងរងគ្រោះថ្នាក់ ដោយសារការទាក់ចាប់ការបរបាញ់ដើម្បីធ្វើពាណិជ្ជកម្ម " និងនាំចេញទៅបរទេសសម្រាប់បម្រើឱ្យការធ្វើពិសោធន៍ស្រាវជ្រាវប្រភេទថ្នាំព្យាបាលជំងឺផ្សេងៗ ព្រោះលក្ខណៈចិត្តសាស្ត្រ និងរូបសាស្ត្ររបស់ពានរមានភាពស្រដៀងគ្នាច្រើននឹងចិត្តសាស្ត្រ ឬរូបសាស្ត្ររបស់មនុស្ស។ រីឯប្រភេទខ្លះទៀតត្រូវស្លាប់ដោយសារមានមេរោគចម្លង ( Zonotic Diseases )។





# ស្វាក្ដាម

## LONG-TAILED MACAQUE MACACA FASCICULARIS

**រូបរាង ៖** ស្វាក្ដាមមានការផ្លាស់ប្ដូរពណ៌ពីរដំណាក់កាល សំខាន់ៗ គឺពណ៌ប្រផេះលាយត្នោត និងពណ៌ក្រហមភ្លឺចំពោះការផ្លាស់ប្ដូរពណ៌នេះប្រែប្រួលទៅតាមអាយុកាល ភេទ និង ទីតាំង រស់នៅរបស់វា។



ជាទូទៅ វាមានពណ៌ពីប្រផេះភ្លឺ ទៅពណ៌ក្រហមភ្លឺពេល ដែលរស់នៅក្នុងព្រៃ ចំណែកឯពពួកស្វារស់នៅមាត់សមុទ្រ ភាគច្រើនមានពណ៌ភ្លឺឆើតជាងប្រភេទដែលរស់នៅតាមតំបន់ ផ្សេងៗទៀត។ ស្វាក្ដាមមានប្រវែងពីក្បាលដល់កន្ទុយ ៩២ -១០៩ស.ម ហើយកន្ទុយរបស់វាវែងជាងគេក្នុងចំណោមប្រភេទស្វានានានៅទ្វីបអាស៊ី។ កូនរបស់វាកើតមកមានពណ៌ខ្មៅ។ ចំពោះស្វាមិនទាន់ញវ័យមានដុះរោមកញ្ចុំវែងៗលើក្បាល ចំណែកស្វាចាស់វិញមានរោមវែងក្រាស់ដុះជុំវិញមុខ និងមានថ្ពាសទំពែក។

**ជីវសាស្ត្រ ៖** ស្វាក្ដាមរស់នៅតំបន់ព្រៃស្ទើរតែគ្រប់ប្រភេទ ដូចជា ព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង ព្រៃឫស្សី តំបន់វាលភក់ ព្រៃលិចទឹក ព្រៃកោងកាង តំបន់កសិកម្ម តាមបណ្ដោយឆ្នេរខ្សាច់ និងតាមឆ្នេរកោះ ជាពិសេសវាលភក់។ ចំណីរបស់វារួមមាន៖ ក្ដាម បង្កង ខ្យង ខ្ចៅ គ្រុំ លៀស ងាវ សត្វល្អិត ផ្លែឈើ ផ្កាឈើ និងត្រួយឈើជាដើម។ វាជាប្រភេទស្វាដែលមិនខ្លាចទឹក នឹងមានការស្ទាត់ជំនាញ ក្នុងការហែលទឹក។ ស្វាឈ្មោលអាចមុជទឹកបាន ចម្ងាយរហូតដល់ទៅ ៥០ម៉ែត្រ។ វារស់នៅជាហ្វូងធំរហូតដល់១០០ក្បាល។ ស្វាក្ដាម កូនម្ដងបានតែមួយគត់បន្ទាប់ពីពពោះអស់រយៈពេល៥-៦ ខែ។



**របាយរស់នៅ ៖** មានវត្តមានស្ទើរតែទូទាំងតំបន់ នៃប្រទេសកម្ពុជា។ វាក៏មានវត្តមានផងដែរ នៅតាមប្រទេសនានានៃភូមិភាគអាស៊ីអាគ្នេយ៍រួមមានប្រទេសថៃ ម៉ាឡេស៊ី ហ្វីលីពីន កោះសូម៉ាត្រា បូរណេអូ កោះចាវ៉ា និងកោះបាលី។

**ស្ថានភាពអភិរក្ស ៖** ស្វាក្ដាមស្ថិតក្នុងក្រុមប្រភេទមានដោយបង្គួរ ប្រភេទនេះត្រូវបាន ចុះក្នុងបញ្ជីក្រហម IUCN ជាប្រភេទរងគ្រោះតិចតួច (LR/nt) ។ ប្រភេទនេះកំពុងរងគ្រោះដោយសារការទាក់ចាប់បង្កាត់ពូជដើម្បីធ្វើពាណិជ្ជកម្ម អន្តរជាតិ។